# ការពិត-ការបង្ខំបណ្តេញដោយខុសច្បាប់ លើប្រជាពលរដ្ឋ ១០៥ គ្រួសារ នៅក្រុងព្រះសីហនុ

នៅវេលាព្រឹកថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៧ ក្រុមចម្រុះមួយក្រុមដែលមានខ្លះជាកម្លាំងកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងនគរបាលប្រមាណ ១៥០ នាក់ ប្រដាប់ដោយអាវុធ ដំបងឆក់ ខែល និង ឧស្ម័នបញ្ចេញទឹកភ្នែក បង្ខំបណ្តេញប្រជាពលរដ្ឋ ១០៥ គ្រួសារឱ្យចេញពីភូមិ ៦ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

នៅក្នុងការបង្ក្រាបនោះ កងកម្លាំងសន្តិសុខបានដុតបំផ្លាញផ្ទះអស់ ៦០ ខ្នង ហើយបានប្រើប្រាស់គ្រឿងចក្រធន់ធ្ងន់ជាឈូសឆាយផ្ទះដែលនៅសល់មួយចំនួនទៀតទាំងស្រុង។ កងកម្លាំងទាំងនោះពុំបានអនុញ្ញាតឱ្យគ្រួសារ ដែលត្រូវបណ្តេញចេញនោះចូលទៅយកសំភារៈសេសសល់ពីក្នុងផ្ទះមុននឹងសំភារៈទាំងនោះត្រូវបំផ្លាញឡើយ ដែលបណ្តាលឱ្យបាត់បង់នូវឯកសារនានា ដែលមានសារសំខាន់ក្នុងកិច្ចការពារករណីរបស់ពួកគេនៅចំពោះមុខតុលាការ ។ លទ្ធផលនៃការប៉ះទង្គិចគ្នារវាងអាជ្ញាធរ និង អ្នកភូមិបណ្តាលឱ្យកម្លាំងនគរបាល ២ នាក់ និង កងរាជអាវុធហត្ថ ១នាក់ ព្រមទាំងអ្នកភូមិមួយចំនួនរងរបួស។ អ្នកភូមិ ១៣ នាក់ត្រូវបានចាប់ខ្លួន ហើយក្រោយមកត្រូវបានចោទប្រកាន់ពីបទ "បំផ្លិចបំផ្លាញទ្រព្យសម្បត្តិខុសច្បាប់" (មាត្រា ៥២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល[២]) ការចោទប្រកាន់អំពីការបំផ្លិចបំផ្លាញឧបករណ៍របស់នគរបាល ដែលប្រើប្រាស់នៅក្នុងការបង្ក្រាប និង "ការវាយដំបណ្តាលឱ្យមានរបួស" នោះគឺធ្វើឡើងដោយផ្អែកលើ (មាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)។



[២] មាត្រាក្នុងច្បាប់ព្រហ្មទណ្ឌ និង តុលាការ និង នីតិវិធីអនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល អនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ កាលពីថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ការបណ្តេញសហគមន៍ដោយបង្ខំកាលពីថ្ងៃទី ២០ មេសា ២០០៧ កន្លងទៅនេះ គឺជាសកម្មភាពខុសច្បាប់ ហើយទីបំផុតបណ្តាលឱ្យមានអំពើហិង្សា និង ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងភូមិកើតឡើង ដែលជាលទ្ធផលចេញពីការបណ្តេញនេះ។ ដូច្នេះ ត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀតដើម្បីរកឱ្យឃើញពីការដែលអាជ្ញាធរទទួលខុសត្រូវពីមូលហេតុដែលបង្ករឱ្យមានអំពើហិង្សានេះកើតឡើង។

**ចំណុចទី១** បញ្ហាកម្មសិទ្ធិលើដីមានទំនាស់មិនទាន់ត្រូវបានដោះស្រាយនៅឡើយ។ គណៈកម្មាធិការស៊ុរិយោដី និងប្រព័ន្ធច្បាប់តុលាការកម្ពុជាពុំអាចបញ្ជាក់ថា ភាគីណាមួយក្នុងចំណោមភាគីជម្លោះទាំងពីរជាម្ចាស់ដីនោះទេ ។ ការអះអាងថា ភាគីមួយមានប័ណ្ណកម្មសិទ្ធិដីនោះ ក៏បញ្ហានេះនៅមិនទាន់មានស្ថាប័នណាមួយបញ្ជាក់ឱ្យច្បាស់នៅឡើយដែរ។ ដូច្នេះ ការបញ្ជារបស់សាលាក្រុងព្រះសីហនុឱ្យបណ្តេញពលរដ្ឋក្នុងសហគមន៍ចេញមុនមានការសម្រេចថា ភាគីណាមួយជាម្ចាស់កម្មសិទ្ធិនោះគឺ ជាអំពើខុសច្បាប់ ហើយត្រូវតែមានការស៊ើបអង្កេតដោយឯករាជ្យមួយ ។

ការស៊ើបអង្កេតនេះត្រូវបានជួយបំភ្លឺបន្ថែមដោយលទ្ធផលស្រាវជ្រាវរបស់គណៈកម្មាធិការសិទ្ធិមនុស្ស និង ទទួលពាក្យបណ្តឹងនៃព្រឹទ្ធសភា ហើយការស៊ើបអង្កេតនេះត្រូវបានចេញផ្សាយកាលពីថ្ងៃទី ៨ ខែកុម្ភៈ **ឆ្នាំ**២០០៧ កន្លងទៅ ដែលជាការឆ្លើយតបទៅនឹងញត្តិរបស់ប្រជាពលរដ្ឋ ៥៣ នាក់ដែលបានតវ៉ាជំទាស់នឹងការបាត់បង់ដីរបស់ពួកគេ។ ក្រោយពីបានសម្ភាសចៅហ្វាយក្រុងព្រះសីហនុរួចហើយគណៈកម្មាធិការព្រឹទ្ធសភាបានធ្វើសេចក្តីសន្និដ្ឋានថា បញ្ហាទំនាស់ដីធ្លីនេះតម្រូវឱ្យមានការដោះស្រាយតាមច្បាប់តុលាការកម្ពុជា ។




ទោះបីជាមានអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃព្រឹទ្ធសភាយ៉ាងណាក្តី ក៏សាលាក្រុងព្រះសីហនុនៅតែបន្តត្រៀមធ្វើការបណ្តេញប្រជាពលរដ្ឋចេញពីសហគមន៍នោះដដែល។

**ចំណុចទី ២** ការដេញប្រជាពលរដ្ឋនៅថ្ងៃទី ២០ ខែមេសា ពុំមានការជូនដំណឹងឱ្យប្រជាពលរដ្ឋក្នុងសហគមន៍បានដឹងជាមុនទេ ។ សាលាក្រុងព្រះសីហនុបានអះអាងថា ការប្រើប្រាស់កងកម្លាំងសន្តិសុខព្រមទាំងគ្រឿងចក្រឈូសឆាយដីគឺបានធ្វើឡើងដោយផ្អែកលើដីកាផែកឆេរលំនៅដ្ឋាន ដែលសាលាក្រុងទទួលបានពីការិយាល័យព្រះរាជអាជ្ញាអមតុលាការក្រុងព្រះសីហនុតបតាមសំណើរបស់ខ្លួនចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៧ ។ សហគមន៍ដែលរងផលប៉ះពាល់ និង មេធាវីការពារក្តីនៅពុំទាន់ទទួលបានដីកានោះនៅឡើយទេ ។

អនុលោមតាមមាត្រា ២០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា "*ការផែកឆេរអាចធ្វើទៅបានលុះត្រា តែមានវត្តមានជនសង្ស័យ និង សាក្សី ២ នាក់ ហើយសាក្សីដែលល្អ គឺអ្នកជិតខាង និង ម្ចាស់អាគារ*" ។ ការរំលោភដោយមន្ត្រីសាធារណៈលើសិទ្ធិបុគ្គលដូចមានចែងក្នុងមាត្រា ២០ នឹងត្រូវមានទោសព្រហ្មទណ្ឌ យោងតាមមាត្រា ២២ (២) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ លើសពីនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំអនុញ្ញាតឱ្យប្រើកម្លាំងយោធាអនុវត្តដីកាឆែកឆេរលំនៅដ្ឋានជនស៊ីវិលទេ ដែលកិច្ចការនេះ គឺជាបុព្វសិទ្ធិរបស់នគរបាលតុលាការតែប៉ុណ្ណោះ ។

**<u>ព័ត៌មានបន្ថែម សូមមេត្តាទាក់ទង:</u>**


១-លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ - ០១២ ៩៤០ ៦៤៥

២-លោក ហាម ស៊ុនរិទ្ធ មេធាវីសិទ្ធិមនុស្សជាន់ខ្ពស់- ០១២ ៩៨៨ ៩៥៩

៣-Mr. Hornung Manfred ទីប្រឹក្សាផ្នែកច្បាប់ - ០១២ ៩៧៩ ៦០៧